សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# EXTRACTIVE INDUSTRIES NEWSLETTER

Issue 17th

May 2013




Map of offshore oil in Cambodia (Picture CNPA)

## Oil Production to Start with Concerns in 2016

By Mr. Vong Sopheap

Phnom Penh: NGOs expressed their concerns when Cambodia will soon have its first drop of oil over the improper management of revenue and its root-cause for corruption.

Cambodia was initially planned for oil production in 2012, but was procrastinated until 2016.

These concerns were raised during a round table discussion on “Petroleum Exploitation and Economic Development” organized by the Club of Cambodian Journalists under the financial support of Conrad Foundation at the Cambodiana Hotel.

Chhay Sarath, Cambodians for Resource Revenue Transparency Executive Director voiced over two main problems which are the concerns of civil society of 1) the government is yet fully understood the impact of economic revenue and 2) the corruption itself. Oil and gas revenues are non-renewable resources. The expected life cycle for oil pumping in Cambodia is around 30 years. When these resources are gone, how can we continue to develop our country’s economy?

“Cambodia is divided into 25 onshore and offshore blocks. 6 are off-shores and 3 are onshore which

Continued on page 5

## Getting Mining and Oil Contracts into the Light, Online

By Jed Miller

In the global effort to follow mining and oil money more closely, the payments from companies to governments and the spending by those resource-rich governments usually draw the greatest scrutiny. But before a dollar changes hands, the rules of the game often get set in contracts that citizens (and sometimes even their elected representatives) rarely see.

Last week at World Bank headquarters in Washington, D.C., Revenue Watch and the World Bank Institute announced a new tool in the push to make contracts easier to find, and a little easier to understand. Working with Columbia University, NGO colleagues and technology leaders, we have launched a web database of mining and oil contracts, beginning with about 100 documents from the African mining and oil sectors.

Continued on page 3

## Contents

- Oil Production to Start ............... 1
- Getting Mining and Oil ............... 1
- New rules for oil, gas sector...... 2
- EU seals deal to boost .............. 4
- The Philippine Implementation ... 4
- Tougher Life for Greater ............ 6



## New rules for oil, gas sector vital to meet emissions target: report

By Stephanie Levitz

OTTAWA -- The oil and gas sector will need to lower greenhouse gas emissions by 42 per cent if Canada has any hope of meeting overall reductions targets by the end of the decade, says a new report from an environmental think-tank.

The Pembina Institute report also says the only way that's going to happen is if upcoming federal regulations on the sector go much farther than those already in place in Alberta.

The Conservative government has been promising new rules for the oil and gas sector since 2008 and has suggested they will finally be unveiled this year.

They'll follow earlier regulations for the transportation and electricity sectors, all aimed at reducing Canada's greenhouse gas emissions by 17 per cent from 2005 levels by 2020.

Both the environmental commissioner and the now-defunct National Round Table on the Environment and the Economy warned last year that Canada was not on track to meet that goal.

A federal government report last summer, however, said Canada was already halfway there.

The oil and gas sector is responsible for about 22 per cent of all emissions, making the rules governing the sector the most critical, the institute said Tuesday in releasing its report.

It's a make-or-break moment for Canada's climate credibility, said Clare Demerse, the think-tank's director of federal policy.

"This is an industry that has been under microscope, it is facing more and more scrutiny of its environmental track record, and having strong regulations in place would help to answer its critics (and) would help to increase public support for the sector's operations," Demerse said.

The institute would rather see an overarching approach to emissions reductions, rather than the government's current sector-by-sector rules, Demerse said. But the Conservatives are likely to model their regulations after the precedent-setting regime already in place in Alberta, she added.

There, companies can voluntarily reduce emissions, make payments in lieu of reductions to a technology fund, or purchase so-called carbon offsets.

If the federal government is going to follow that model, it is needs to go father, the report said.

Rather than charge $15 a tonne for a technology fund, as Alberta does, the federal rules should charge at least $100 per tonne by 2020, the report recommends.

If companies are indeed allowed to buy offsets, the government will have to ensure they actually represent emissions reductions, it adds.

"A higher target sends a stronger signal to oil and gas companies that they need to reduce their emissions, and the funds they provide to a technology fund or to offset projects mean increased investment in projects that cut GHG pollution in other sectors as well."

In fact, the reduction goals aren't so out of line with an old Conservative pledge on GHG emissions from 2008 that aimed to cut the oil and gas sector's contributions by 37 per cent, Demerse noted.

The Conservatives, meanwhile, have insisted a tax on carbon of any kind is not on the table. The government is committed to getting levels down -- but not at all costs, Natural Resources Minister Joe Oliver said Tuesday.

"One sure way to reduce greenhouse gas emissions -- and it's been done in a lot of countries -- is to have the economy collapse," Oliver said.

"That's not the route our government wants to take." (Source: CTV News)



Continued from page 1 **Getting Mining...**

Using this new site, viewers can filter contracts by country and natural resource, and read summaries of dozens of key provisions in each contract. Perhaps most significantly, readers can review each document, page by page, even if they are not able to view or download PDF files. In many countries and regions, slow Internet speeds make the download of PDFs impossible, or prohibitively slow.

Advocates and officials from all sectors are paying increasing attention to the transparency of mining and oil contracts, and the monitoring that can turn better rules into better behavior. "If contracts remain opaque," says the international Publish What You Pay coalition, "citizens have no way of knowing whether they are getting a fair deal for their resources and no means of finding out where the money goes."

Several groups have taken steps toward greater dissemination of these contracts, which control billions of dollars in government revenue and potential gain for local communities. In Afghanistan, the mining ministry has published hundreds of documents, and efforts in the Democratic Republic of Congo and Sierra Leone have included attention to contracts.

In 2012, the government of the Republic of Guinea formally announced a systematic review of all its mining contracts, as part of a mining sector overhaul. A key commitment of the 2011 mining code is the publication of all the country's mining contracts. Revenue Watch and WBI are honored to have the chance to use the new technology to support this effort by Guinea's Committee for the Review of Mining Contracts and Licenses. The committee's web site is expected to be launched during February.

Our January 24 "brown bag" presentation at the World Bank gathered an audience of nearly 70 people from Bank staff, government, NGOs and the private sector. After our talk on the goals and features of the contracts tool, we received comments from guests Michael Stanley, mining lead from the Bank's Sustainable Energy, Gas, Oil and Mining Team (SEGOM), and Isabel Munilla, who runs the Publish What You Pay US coalition. Stanley focused in the question of training for government and civil society members seeking to better understand the oil and mining contract process. We must work to fill the "capacity building gap," he said, in order for groups in resource-rich countries to use tools like this one to their best advantage.

Munilla, whose coalition led the victorious campaign for new U.S. disclosure laws governing company mining and oil payments to governments, asked how the online repository might also serve as an incentive—or a lever—for more governments to release more extractive sector contracts. Stanley also reminded the group that any contract is only the end result of a lengthy bidding and negotiation process; these activities also should be more available to public scrutiny.

While a lack of contract transparency is sometimes a policy problem, it can often be a problem of government efficiency or political will in diss eminating documents, even if the law makes them technically public. How transparent is a contract, really, if the only copy resides in a cabinet in a ministry office, 1,000 miles from a village whose residents seek some benefit from the mining in their region? Even if a contract is on the web, government web sites crash often, and users in remote locations may not be able to read a large PDF document using their slow internet connection.

To lessen some of these challenges, our web tool is based on Document Cloud, a system used by journalists, advocates and citizens to support greater information access by improving dissemination and display of government documents, official records and contracts. The site was built in partnership with Development Seed, pioneers in the open data community and creators of state of the art maps and tools for UNDP, FAO, the World Bank, among others. Source: www.goxi.org

## EU seals deal to boost transparency of oil, gas and logging firms

By Marc Hall

Payments of more than €100,000 to governments in resource-rich countries must be declared, as EU agrees landmark law fight tax evasion and corruption.

The EU has adopted new laws aimed at increasing the transparency of government payments from the oil and gas industry, in a move hailed by U2 frontman Bono as a "game changing breakthrough" on corruption in resource-rich developing countries.

Ministers, the European commission and parliament on Tuesday ended negotiations on the accounting directive by agreeing a compromise proposal, after fierce lobbying from industry and NGOs. The deal requires European companies to report payments of more than €100,000 (£85,000) made to the government in the country they are operating in, including taxes levied on their income, production or profits, royalties, and licence fees.

The EU executive will oblige companies to disclose the payments they make at project level as opposed to government level only, revealing the sources of taxable government income from the extraction or logging industries.

Bono, the singer and co-founder of poverty campaign group one, said: "Europe's leaders have stepped up and delivered a game changing breakthrough tonight. Transparency is one of the best vaccines against corruption, and now citizens the world over will know what their country's resources are really worth."

The agreement will also cut red tape for small and medium-sized enterprises (SMEs) by simplifying accounting rules.

The deal goes beyond disclosure rules adopted by the US last year by including the logging industry along with mining and petroleum operations.

"The agreement will bring in a new era of transparency to an industry which is far too often shrouded in secrecy, and help fight tax evasion and corruption, as well as create the framework so both companies and governments can be held to account on the use of revenues from natural resources," said Michel Barnier, the European commissioner for the internal market.
Source: The Guardian

## The Philippine Implementation of the Extractive Industries Transparency Initiative

The Government of the Philippines, the Chamber of Mines of the Philippines, and Bantay Kita welcome the Aquino Administration's decision to implement the Extractive industries Transparency initiative (EITI) in the Philippines, indeed, greater transparency and accountability in the payment, collection, and utilization of taxes and other revenues from extractive industries will greatly contribute in ensuring that such will be used for the benefit of the country and its citizens.

In so doing, we must emphasize that at the heart of EITI is a paradigm for free, open, inclusive and sincere dialogue and collaboration between government, industry and civil society. We use EITI, an international standard for revenue disclosure, to achieve this purpose.

With this, the Government of the Philippines, the Chamber of Mines of the Philippines, and Bantay Kita, have agreed to link arms to implement EITI. We have formed an interim multi-stakeholder group that will steer all the necessary activities leading to the Philippines' filing of an application for EITI Candidacy before the end of 2012.

The EITI International Board has promulgated five requirements for countries seeking to be an EITI Candidate, Three of which have been fulfilled: the government's unequivocal public statement of its intention to implement EITI; its commitment to work with civil society and companies in this initiative; and the appointment of an EITI lead senior government official.

We, the members of the interim EITI Philippines, may happen to come from different perspectives and backgrounds. But today, we unite to push for greater transparency, accountability and open dialogue among stakeholders in the collection and payment of taxes and revenues from extractive industries.
Source: www.gov.ph



Continued from page 1 **Oil Production...**

are 12, 15 and 17. These blocks were awarded to foreign companies. It is notable that Cambodia also has the most potential overlapping claim area with Thailand," claimed Chhay Sarath.

Dinis Schrey, representative of Conrad Foundation in Cambodia said Cambodia is very much concerned over the petroleum industry focusing on its management and revenue generation. The International Monetary Fund estimated that the revenues from this sector will increase from year to year and there will be a significant increase of USD 1.7 billion in 2021. However, this is just an estimate. The price may be volatile depending on the global market. If the estimate can become reality, then infrastructures will be improved and poverty will be alleviated.

"However, without proper management over revenues and its corruption, possible risk of having big gaps between the rich and the poor will surely be unavoidable," said Denis Schrey. "Cambodia petroleum industry is a new sector compared to other sectors. However this industry will contribute to the economic development of the country," he added.
Schrey confirmed that Cambodia has potential oil and gas, the once considered as black gold, and this attracts many foreign companies from USA, Australia, China, Indonesia, Japan and even Korea to invest in exploring underground from block A to F and other onshore blocks.

"The government only provides very limited and imprecise information on investment companies. Corruption happens worldwide when it comes to natural resource exploration. I believe the Cambodian National Petroleum Authority and the Council of Ministers will do their best to ensure transparency and commit to disclose to the public. Also, the National Assembly and Civil Society Organizations play vital roles in helping ensure transparency in natural resource exploration," added Schrey.

The Cambodian National Petroleum Authority could not be reached for comments.

Continued from page 6 **Tougher Life...**

when we want it to happen. It is not wise to set to a particular place for education as this could then be eliminated by what we are going to share," said Nin.

"I have always thought that extractive industry is never be my job to get involved, but when getting myself fully engaged, I understand that everyone is entitled to it and should, no doubt, get to know for oneself perception and for the country's benefits. I realize that revenue from extractive industry is huge that can reverse a country from being poverty-stricken to become economically prosperous in the conditions that it is well-managed, otherwise this can never avoid the so-called resource curse. I have also noted that much detrimental environmental and social impact is to be minimized to the lowest possible," added Nin.

However, despite the fact that Nin has acquainted extractive industry knowledge, it is still yet fundamental, that could allow her to deal with technical questions when queried during mobilization.

"Words can never express how grateful and joyful I have been under the guidance of Cambodians for Resource Revenue Transparency. Without being admitted as a volunteer, I would have never have been as of today, perceiving the knowledge of extractive industries," uttered Nin."

"Last but not least, I would like to make an appeal to donor agencies to please continue to support the work of Cambodians for Resource Revenue Transparency, the only agency working on extractive industry to bring about transparency and accountability in revenue from oil, gas and mining," said Nin.

## Tougher Life for Greater Extractive Industry Knowledge

By CRRT



Ms. Chim Nin is planting trees

Born to a yokel family in a not-so-developed province was a dream far-fetched to be turned into reality. Living off paucity to survive from hand to mouth was another extreme issue. Seeking for tertiary education always was a hindrance of budget constraint.

Ms. Chim Nin commenced her education from the lower to the higher strata in her own hometown prior to moving into the city where she found herself dwelling in an environment where knowledge is well taken into cognizance.

Nin is currently the year-four student at the Royal University of Phnom Penh, faculty of social science and humanity, majoring sociology.

Nin cannot be yet self-sustained, thus studying while volunteering endeavors are inevitable.

Since her very first footstep into town, hearing various investiture development projects on extractive industries, keeps her wondering and pondering to the connotation laying behind it. On a resistant desire to know, she commits herself to doing research, seeking any work-related opportunities until she ultimately be recruited by the Youth Resource Development Program as a volunteer core group youth action for extractive industry transparency and climate change unit project. Nin gained so much knowledge on how to facilitate extractive industry workshops and in group in the cities and at provinces. Writing basic invitation letters, thank you letter, organizing and scheduling exposure trips, interviewing and gathering data have been her successes.

Nin has engaged herself in several training courses as well as inter-generational dialogs on social, environmental and mining activities. Her capacity was also built through courses of statistical package of social science, social accountability in the extractive industries, extractive industry mining, oil and gas, climate change and other related lessons.

Nin volunteering contract period came to an end in a swift, but with so much determination and commitment, she strives endlessly until she was then accepted to work with Cambodians for Resource Revenue Transparency, a specialized coalition with members to ensure transparency and accountability in revenue from oil, gas and mining as a volunteer.

"I start to understand and get to know the concept of extractive industries only when I am on-the-job training through my volunteering work. I feel it is my responsibility as a citizen of a country rich in natural resource of oil, gas and mining to learn its importance and what contributions will be made when production start in 2016. I am indeed so fortunate to be bestowed with so many trainings. I am proud and delighted to know and to be able to share among friends and relatives about extractive industries," said Nin.

With the knowledge learned, Nin has mobilized and shared her assets with other university students as well as associate members through any means possible at forums, workshops, trainings, conferences and even at recreation sites. "Education takes no consideration of places! It happens

Continued on page 5

**The opinions expressed herein are those of the authors and do not necessarily reflect the views of all donors.**

MISEREOR DAS HILFSWERK · USAID FROM THE AMERICAN PEOPLE · REVENUE WATCH INSTITUTE · Oxfam · NORWEGIAN PEOPLE'S AID



CRRT: #88, St. 468, Tuol Tompoung I, Khan Chamkamon, Phnom Penh, Cambodia
Tel: 855-23-217-607, Website: www.crrt-cambodia.org

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# ព្រឹត្តប័ត្រព័ត៌មាន ឧស្សាហកម្មនិស្សារណកម្ម

លេខ ១៧
ឧសភា ២០១៣




ផែនទីប្លុកប្រេងក្នុងដែនសមុទ្រកម្ពុជា(រូបថត CNPA)

## ការធ្វើអាជីវកម្មប្រេងចាប់ផ្តើមឆ្នាំ២០១៦ជាមួយនឹងការបារម្ភ

ដោយ វង្ស សុភាព

ភ្នំពេញៈ ក្រុមអង្គការសង្គមស៊ីវិលបានសម្តែងក្តីព្រួយបារម្ភរបស់ខ្លួននៅពេលដែលកម្ពុជាទទួលបានតំណក់ប្រេងដំបូងបំផុតនាពេលខាងមុខនេះ ដោយពួកគេខ្លាចមានការប្រើប្រាស់ធនធានប្រេងដែលទទួលបានមិនបានត្រឹមត្រូវ និងកើតមានអំពើពុករលួយ ។

ផែនការដំបូង ប្រទេសកម្ពុជាបានរំពឹងទុកថាអាចនឹងចាប់ផ្តើមធ្វើអាជីវកម្មប្រេងនៅឆ្នាំ២០១២ ប៉ុន្តែផែនការនេះមិនអាចធ្វើទៅបាន ហើយត្រូវបានកំណត់ពេលវេលាជាថ្មីក្នុងឆ្នាំ២០១៦។

ការព្រួយបារម្ភរបស់អង្គការក្រៅរដ្ឋាភិបាលបានលើកឡើងនៅក្នុងវេទិកាតុមូលស្តីពីការធ្វើអាជីវកម្មប្រេង និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលរៀបចំដោយក្លឹបអ្នកកាសែតកម្ពុជាក្រោមការឧបត្ថម្ភដោយមូលនិធិខុនរ៉ានអាដេណៅអ៊ែ កាលពីពេលកន្លងទៅនេះនៅសណ្ឋាគារកាំបូឌីយ៉ាណា ។

នាយកប្រតិបត្តិសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធានលោក ឆាយ សារ៉ាត បាន និយាយថា មានបញ្ហាធំពីរដែលជាការព្រួយបារម្ភរបស់សង្គមស៊ីវិលគឺ ទី១ ទាក់ទងទៅនឹងការប្រើប្រាស់ធនធានមិនបានត្រឹមត្រូវ គឺរដ្ឋាភិបាលមិនបានយល់ដឹងពីផលប៉ះពាល់ច្រើន អំពីចំណូលទៅលើសេដ្ឋកិច្ច និងទី២ អំពើពុករលួយ។ ចំណូលពីវិស័យប្រេងនិងឧស្ម័នដែលជាថាមពលមិនអាចកកើតឡើងវិញបានមានអាយុកាលនៃការបូមប្រេងនៅកម្ពុជា ៣០ឆ្នាំ ហើយប្រសិនបើអស់ប្រេង តើយើងមានថវិកាឯណាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច?

លោក ឆាយ សារ៉ាត បានលើកឡើងថា ប្រទេសកម្ពុជាត្រូវបានបែងចែកទៅជា២៥ប្លុក មានទាំងតំបន់ដែនគោក និងតំបន់ដែនទឹក។ តំបន់ដែនទឹកមាន៦ប្លុក ត្រូវបានផ្តល់

តទៅទំព័រ ៥

## យកកិច្ចសន្យារ៉ែនិងប្រេងដាក់បង្ហាញតាម Online

ដោយ Jed Miller

តាមរយៈកិច្ចខិតខំប្រឹងប្រែងជាសាកលដើម្បីតាមដានឲ្យបានជិតដល់នូវទឹកប្រាក់បានមកពីរ៉ែ និងប្រេង ការបង់ប្រាក់របស់ក្រុមហ៊ុនជូនរដ្ឋាភិបាលព្រមទាំងការចំណាយរបស់រដ្ឋាភិបាលប្រទេសសម្បូរធនធានជាធម្មតាមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់បំផុត។ ប៉ុន្តែមុនពេលក្រដាសប្រាក់មួយដុល្លាប្រគល់ទៅឲ្យនរណាផ្សេង ច្បាប់ជាយុទ្ធសាស្ត្រ ត្រូវមានចែងក្នុងកិច្ចសន្យាដែលប្រជាពលរដ្ឋកម្រនឹងបានឃើញ (ហើយជូនកាលសូម្បីតែអ្នកដែលត្រូវបានជ្រើសរើសជាតំណាងក៏មិនបានឃើញដែរ)។

កាលពីសប្តាហ៍មុនការិយាល័យរបស់ធនាគារពិភពលោកក្នុងទីក្រុងវ៉ាស៊ីងតោនឌីស៊ី វិទ្យាស្ថានឃ្លាំមើលចំណូល និងធនាគារពិភពលោកបានប្រកាសនូវឧបករណ៍ថ្មីមួយក្នុងការជម្រុញធ្វើឲ្យកិច្ចសន្យាមានភាពងាយស្រួលជាងមុនក្នុងការរក និងស្វែងយល់។ សហការជាមួយសាកលវិទ្យាល័យ កូឡុំប៊ី សហសេវិកដែលអង្គការមិនមែនរដ្ឋាភិបាល និងមេដឹកនាំបច្ចេកវិទ្យាបានដាក់ឲ្យដំណើរការគេហទំព័រទិន្នន័យមួយអំពីកិច្ចសន្យារ៉ែ និងប្រេងដែលជាការចាប់ផ្តើមដំបូងមានឯកសារប្រហែលជា១០០ មកពីវិស័យរ៉ែ

តទៅទំព័រ ៣

### មាតិកា

ការធ្វើអាជីវកម្មប្រេង ........................ ១
យកកិច្ចសន្យា ........................................ ១
ច្បាប់ថ្មីសម្រាប់វិស័យប្រេង ............. ២
សហគមន៍អឺរ៉ុប ..................................... ៤
ហ្វីលីពីនប្រតិបត្តិគំនិតផ្តួចផ្តើម ....... ៤
តស៊ូក្នុងជីវិត ..................................... ៦



## ច្បាប់ថ្មីសម្រាប់វិស័យប្រេង ឧស្ម័នមានសារៈសំខាន់ដើម្បីសម្រេចបានគោលដៅកាត់បន្ថយការបំភាយ: របាយការណ៍

ដោយ Stephanie Levitz

អូតាវ៉ាៈ វិស័យប្រេង និងឧស្ម័ន នឹងត្រូវកាត់បន្ថយការបំភាយចេញនូវឧស្ម័នផ្ទះកញ្ចក់ឲ្យបានចំនួន ៤២ ភាគរយប្រសិនបើប្រទេសកាណាដាមានក្តីសង្ឃឹមក្នុងការសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយជាទូទៅនៅចុងទស្សវត្សនេះ នេះបើយោងតាមរបាយការណ៍ថ្មីពីក្រុមប្រឹក្សាយោបល់បរិស្ថាន។

របាយការណ៍របស់វិទ្យាស្ថាន Pembina រាយការណ៍ផងដែរថា មធ្យោបាយតែមួយគត់ដែលអាចធ្វើទៅបានគឺ ប្រសិនបើបទបញ្ញត្តិរបស់សហព័ន្ធស្តីពីវិស័យនេះអាចមានលក្ខណៈស៊ីជម្រៅជាងបទបញ្ញត្តិដែលមានស្រាប់នៅអាល់បឺតា ។

រដ្ឋាភិបាលអភិរក្សបានធ្វើការសន្យាឲ្យមានច្បាប់ថ្មីសម្រាប់វិស័យប្រេង និងឧស្ម័ន ចាប់តាំងតែពីឆ្នាំ ២០០៨ មក ហើយបានផ្តល់ជាយោបល់ថាច្បាប់នេះក៏នឹងត្រូវបានប្រកាសក្នុងឆ្នាំនេះដែរ។

ច្បាប់នេះនឹងអនុលោមតាមបទបញ្ញត្តិសម្រាប់ការដឹកជញ្ជូន និងវិស័យអគ្គិសនី ក្នុងគោលបំណងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ឲ្យបានចំនួន ១៧ ភាគរយ ពីកម្រិតឆ្នាំ ២០០៥ នៅឆ្នាំ ២០២០។

ទាំងសមាជិកគណៈកម្មការបរិស្ថាន និងកិច្ចពិភាក្សាតុមូលថ្នាក់ជាតិ ស្តីពីបរិស្ថាន និងសេដ្ឋកិច្ច ដែលបច្ចុប្បន្នបានបាត់បង់ទៅហើយនោះ បានធ្វើការព្រមានកាលពីឆ្នាំមុនថា ប្រទេសកាណាដាមិនបានដើរតាមគន្លងត្រឹមត្រូវ ដើម្បីសម្រេចបានគោលដៅនោះទេ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍នារដូវក្តៅឆ្នាំមុនរបស់រដ្ឋាភិបាលសហព័ន្ធ បានរាយការណ៍ថាប្រទេសកាណាដាបានដើរដល់ពាក់កណ្តាលផ្លូវហើយ ។

វិស័យប្រេង និងឧស្ម័នទទួលខុសត្រូវប្រហែលជាចំនួន ២២ ភាគរយ នៃការបំភាយទាំងអស់ នាំឲ្យច្បាប់គ្រប់គ្រងវិស័យនេះមានសារៈសំខាន់ណាស់ នេះបើតាមរបាយការណ៍របស់វិទ្យាស្ថានដែលបានចេញផ្សាយកាលពីថ្ងៃអង្គារ។

លោកស្រី Clare Demerse នាយកក្រុមប្រឹក្សាយោបល់នៃគោលនយោបាលសហព័ន្ធបានមានប្រសាសន៍ថានេះជាវេលាដែលអាចទទួលជោគជ័យ ឬបរាជ័យសម្រាប់កេរ្តិ៍ឈ្មោះផ្នែកអាកាសធាតុរបស់ប្រទេសកាណាដា ។

លោកស្រី Demerse បានបន្ថែមថា "នេះជាឧស្សាហកម្មមួយដែលស្ថិតក្រោមការត្រួតពិនិត្យឲ្យបានហ្មត់ចត់ ដែលករណីនេះវាកំពុងតែប្រឈមទៅនឹងការពិនិត្យកាន់តែលម្អិតខ្លាំងឡើងៗពីកំណត់ត្រាបរិស្ថានហើយមានបទបញ្ញត្តិតឹងរឹងសម្រាប់ឆ្លើយតបទៅនឹងអ្នកទិតៀន ហើយនឹងជួយពង្រឹងការគាំទ្រជាសាធារណៈលើប្រតិបត្តិការវិស័យនេះ" ។

លោកស្រី Demerse បាននិយាយថា វិទ្យាស្ថានចង់ឃើញមធ្យោបាយមួយដ៏ទូលំទូលាយចំពោះការកាត់បន្ថយការបំភាយ ជាជាងការប្រើប្រាស់ច្បាប់តាមវិស័យរបស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន។ ក៏ប៉ុន្តែ អ្នកអភិរក្សនិយមហាក់បីដូចជាមានបំណងចង់យកគំរូបទបញ្ញត្តិរបស់ខ្លួនទៅតាមរបបមុនដែលមាននៅអាល់បឺតា ។

នៅទីនោះ ក្រុមហ៊ុនអាចកាត់បន្ថយការបំភាយដោយស្ម័គ្រចិត្ត ដោយធ្វើការបង់ប្រាក់សម្រាប់ការកាត់បន្ថយជាមុនដល់មូលនិធិបច្ចេកវិទ្យា ឬជាវនូវការកាត់បន្ថយការបំភាយកាបូន ឬឧស្ម័នផ្ទះកញ្ចក់ (Carbon Offsets) ។

របាយការណ៍ក៏បានរាយការណ៍ផងដែរថាប្រសិនបើរដ្ឋាភិបាលសហព័ន្ធ នឹងអនុលោមតាមគំរូនេះវាត្រូវការអនុវត្តបន្តទៀត ។

របាយការណ៍ផ្តល់ជាអនុសាសន៍ថាជំនួសឲ្យការបង់ប្រាក់ចំនួន ១៥$ ក្នុងមួយតោនដល់មូលនិធិបច្ចេកវិទ្យាដូចដែលអាល់បឺតាបានអនុវត្តច្បាប់សហព័ន្ធគួរតែកំណត់ឲ្យបង់ប្រាក់ចំនួន ១០០$ ក្នុងមួយតោននៅឆ្នាំ ២០២០។

របាយការណ៍ក៏បានរាយការណ៍ថាប្រសិនបើក្រុមហ៊ុនត្រូវបានអនុញ្ញាតឲ្យជាវនូវការកាត់បន្ថយការបំភាយកាបូនឬឧស្ម័នផ្ទះកញ្ចក់ រដ្ឋាភិបាលត្រូវធានាថាពិតជាតំណាងឲ្យការកាត់បន្ថយការបំភាយ។

" គោលដៅធំជាងនេះផ្តល់ជាសញ្ញាកាន់តែខ្លាំងដល់ក្រុមហ៊ុនប្រេង និងឧស្ម័ន ដែលក្រុមហ៊ុនទាំងនេះត្រូវតែកាត់បន្ថយនូវការបំភាយរបស់ខ្លួន ព្រមជាមួយថវិកាដែលក្រុមហ៊ុនផ្តល់ជូនមូលនិធិបច្ចេកវិទ្យាឬគម្រោងកាត់បន្ថយការបំភាយកាបូន ឬឧស្ម័នផ្ទះកញ្ចក់មានន័យថាការវិនិយោគមានការកើនឡើងចំពោះគម្រោងដែលកាត់បន្ថយការបំពុល GHG ក្នុងវិស័យផ្សេងៗទៀតផងដែរ"។

លោកស្រី Demerse បានកំណត់ចំណាំថា ជាការពិត គោលដៅនៃការកាត់បន្ថយគឺមិនខុសពីការសន្យាបែបអភិរក្សនិយមចាស់ៗទេអំពីការបំភាយ GHG កាលពីឆ្នាំ ២០០៨ ដែលមានបំណងកាត់បន្ថយការបរិច្ចាគពីវិស័យប្រេង និងឧស្ម័នចំនួន ៣៧ ភាគរយ។

រដ្ឋមន្ត្រីក្រសួងធនធានធម្មជាតិ Joe Oliver បានមានប្រសាសន៍កាលពីថ្ងៃអង្គារថា អ្នកអភិរក្សនិយម ក្នុងខណៈជាមួយគ្នាដែរ បានទទូចសុំឲ្យមានការយកពន្ធលើកាបូន មិនថាប្រភេទណាមួយទេដោយមិនចាំបាច់ធ្វើការចរចា។ រដ្ឋាភិបាលប្តេជ្ញាប្រតិបត្តិឲ្យបានល្អ ប៉ុន្តែមិនមែនប្រើគ្រប់វិធីឲ្យខានតែបានទេ។

លោក Oliver បានមានប្រសាសន៍ថា "មធ្យោបាយប្រាកដប្រជាមួយដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ហើយដែលប្រទេសជាច្រើនបានយកមកអនុវត្តគឺធ្វើឲ្យមានវិបត្តិសេដ្ឋកិច្ច។"នោះមិនមែនជាមាគ៌ាដែលរដ្ឋាភិបាលរបស់យើងត្រូវដើរតាមនោះទេ" ។



មកពីទំព័រ ១ យកកិច្ចសន្យា...

និងប្រេងនៅអាហ្វ្រិក។

ការប្រើប្រាស់គេហទំព័រថ្មីនេះ អ្នកមើលអាចជ្រើសរើសកិច្ចសន្យាតាមប្រទេស និងធនធានធម្មជាតិ និងអាចអានអត្ថបទសង្ខេបនៃច្បាប់ជាច្រើនក្នុងកិច្ចសន្យានីមួយៗ។ប្រហែលជាសំខាន់បំផុតនោះគឺ អ្នកអានអាចពិនិត្យមើលឡើងវិញនូវឯកសារនីមួយៗ ម្តងមួយទំព័រៗ បើទោះបីជាអ្នកមិនអាចមើល ឬទាញយកជាឯកសារ PDF បានក៏ដោយ។ តាមប្រទេស និងតំបន់មួយចំនួនអ៊ីនធើណេតមានល្បឿនយឺត នាំឲ្យមិនអាចទាញយកឯកសារPDFបាន ឬក៏មានល្បឿនយឺតពេក។ អ្នកតស៊ូមតិ និងមន្ត្រីអញ្ជើញមកពីគ្រប់វិស័យ កំពុងតែមានចំណាប់អារម្មណ៍ជាខ្លាំងចំពោះតម្លាភាពនៃកិច្ចសន្យា រ៉ែ និងប្រេង ហើយថាការត្រួតពិនិត្យអាចធ្វើឲ្យច្បាប់ដែលប្រសើរហើយ ឲ្យទៅជាការអនុវត្តន៍ដែលកាន់តែប្រសើរឡើងថែមទៀត។ សម្ព័ន្ធ Publish What You Pay អន្តរជាតិនិយាយថា "ប្រសិនបើកិច្ចសន្យានៅតែលាក់កំបាំង ប្រជាពលរដ្ឋគ្មានមធ្យោបាយណាអាចដឹងថាតើពួកគេទទួលបានកិច្ចសន្យាសមស្របសម្រាប់ធនធានរបស់ពួកគេ និងគ្មានវិធីដឹងថាទឹកប្រាក់ទាំងនោះទៅណាទេ"។

ក្រុមជាច្រើនបានចាត់វិធានការបោះជំហានទៅមុខ ឆ្ពោះទៅរកការផ្សព្វផ្សាយកិច្ចសន្យាទាំងនេះដែលគ្រប់គ្រងទឹកប្រាក់រាប់ពាន់លានដុល្លាជាចំណូលរបស់រដ្ឋាភិបាល និងផលប្រយោជន៍ប្រកបដោយសក្តានុពលសម្រាប់សហគមន៍មូលដ្ឋាន។ នៅប្រទេសអាហ្គានីស្ថាន ក្រសួងរ៉ែ បានបោះពុម្ពឯកសាររាប់រយ ហើយកិច្ចខិតខំប្រឹងប្រែងនេះមានក្នុងសាធារណៈរដ្ឋកុងហ្គោ និងសេរ៉ាឡេអូន ក៏មានចំណាប់អារម្មណ៍លើកិច្ចសន្យានេះដែរ។

ក្នុងឆ្នាំ ២០១២ រដ្ឋាភិបាលសាធារណៈរដ្ឋហ្គីនី បានប្រកាសជាសាធារណៈនូវការត្រួតពិនិត្យឡើងវិញនូវរាល់កិច្ចសន្យារ៉ែ ដែលជាផ្នែកមួយនៃការកែទម្រង់វិស័យរ៉ែទាំងមូល។

ការប្តេជ្ញាចិត្តជាសំខាន់នៃច្បាប់រ៉ែឆ្នាំ ២០១១ គឺការបោះពុម្ពនូវរាល់កិច្ចសន្យាទាំងអស់របស់ប្រទេស។ វិទ្យាស្ថានឃ្លាំមើលចំណូល និងធនាគារពិភពលោក មានកិត្តិយសដែលទទួលបានឱកាសប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការកំណែទម្រង់កិច្ចសន្យា និងអាជ្ញាប័ណ្ណរ៉ែរបស់ប្រទេសហ្គីនី។ គេហទំព័ររបស់គណៈកម្មាធិការត្រូវបានរំពឹងថានឹងចាប់ដំណើរការក្នុងអំឡុងខែកុម្ភៈ។

កាលពីថ្ងៃទី២៤ ខែមករាការធ្វើបទបង្ហាញ "ក្រោយពេលសម្រាកអាហារថ្ងៃត្រង់" នៅការិយាល័យធនាគារពិភពលោក ដែលមានសិក្ខាកាមចូលរួមប្រមាណជា ៧០ រូប ជាបុគ្គលិកធនាគារ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជន។ បន្ទាប់ពីកិច្ចពិភាក្សាអំពីគោលបំណង និងចំណុចសំខាន់ៗនៃឧបករណ៍កិច្ចសន្យា យើងបានទទួលយោបល់ពីភ្ញៀវចូលរួម មានលោក Michael Stanley មកពី SEGOM និង កញ្ញា Isabel Munilla ជាអ្នកដឹកនាំសម្ព័ន្ធ PWYP ។ លោក Stanley ផ្តោតជាសំខាន់លើសំណួរនៃការបណ្តុះបណ្តាលសម្រាប់រដ្ឋាភិបាល និងសមាជិកសង្គមស៊ីវិល ក្នុងការទទួលឲ្យបានការយល់ដឹងកាន់តែប្រសើរអំពីដំណើរការកិច្ចសន្យាប្រេង និងរ៉ែ ។ លោក Stanley បានមានប្រសាសន៍ថា យើងត្រូវតែដោះស្រាយនូវ "គំលាតសមត្ថភាព" ដើម្បីឲ្យក្រុមក្នុងប្រទេសសម្បូរធនធានប្រើប្រាស់ឧបករណ៍ទាំងនេះ ទទួលបានអត្ថប្រយោជន៍ល្អបំផុត។

កញ្ញា Munilla ដែលសម្ព័ន្ធភាពរបស់កញ្ញាបានដឹកនាំយុទ្ធនាការប្រកបដោយជោគជ័យសម្រាប់ច្បាប់ថ្មីដែលតម្រូវឲ្យដាក់បង្ហាញការបង់ប្រាក់ជូនរដ្ឋាភិបាលពីសំណាក់ក្រុមហ៊ុនរ៉ែ និងប្រេង បានចោទសួរថា តើការផ្ទុកឯកសារតាម online បែបណាអាចដំណើរការជាគ្រឿងលើកទឹកចិត្ត ឬជាឧបករណ៍ដែលអាចឲ្យរដ្ឋាភិបាលជាច្រើនថែមទៀត ដាក់បង្ហាញនូវកិច្ចសន្យា ក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មឲ្យបានកាន់តែច្រើន។ លោក Standly ក៏បានរំលឹកដល់ក្រុមថា កិច្ចសន្យាណាមួយគឺគ្រាន់តែជាលទ្ធផលចុងក្រោយនៃការដាក់ឲ្យដេញថ្លៃរយៈពេលយូរ និងដំណើរការចរចាប៉ុណ្ណោះ ដែលសកម្មភាពទាំងនេះ គួរតែដាក់ឲ្យសាធារណៈជនអាចពិនិត្យពិច័យបាន។

ខណៈមានកង្វះខាតតម្លាភាពនៃកិច្ចសន្យាជួនកាលក៏អាចជាបញ្ហាគោលនយោបាយ ករណីនេះជានិច្ចកាល អាចជាបញ្ហានៃប្រសិទ្ធិភាពរបស់រដ្ឋាភិបាល ឬសុច្ឆន្ទៈនយោបាយក្នុងការផ្សព្វផ្សាយឯកសារ បើទោះបីជាច្បាប់អនុញ្ញាតឲ្យចែករំលែកតាមបច្ចេកទេសជាសាធារណៈក៏ដោយ។ តើកិច្ចសន្យាមានតម្លាភាពប៉ុណ្ណា បើសិនកិច្ចសន្យានោះគ្រាន់តែមានរក្សាទុកនៅខុទ្ទការល័យក្រសួង ចម្ងាយ ១០០០ ម៉ាល ពីភូមិ ដែលអ្នកស្រុកស្វែងរកប្រយោជន៍ពីរ៉ែក្នុងតំបន់របស់ខ្លួន? បើទោះបីជាកិច្ចសន្យា មាននៅលើគេហទំព័រក៏ដោយ ក៏គេហទំព័ររបស់រដ្ឋាភិបាលជានិច្ចកាលមិនដំណើរការ ហើយអ្នកប្រើប្រាស់នៅតាមតំបន់ដាច់ស្រយាលប្រហែលជាមិនអាចអានឯកសារDPFធំៗតាមរយៈអ៊ីនធើណេតល្បឿនយឺតបានទេ ។

ដើម្បីសម្រួលការប្រឈមទាំងនេះ ឧបករណ៍គេហទំព័ររបស់យើងអាស្រ័យលើកន្លែងស្តុកឯកសារ "Document Cloud" ជាប្រព័ន្ធដែលអ្នកសារព័ត៌មាន អ្នកតស៊ូមតិ និងប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីគាំទ្រការទទួលបានព័ត៌មានទូលំទូលាយ ដោយធ្វើឲ្យកាន់តែប្រសើរឡើងនូវការផ្សព្វផ្សាយ និងការដាក់បង្ហាញឯកសាររដ្ឋាភិបាលកំណត់ត្រាជាផ្លូវការ និងកិច្ចសន្យា។ គេហទំព័រនេះត្រូវបានបង្កើតឡើងសហការជាមួយ Development Seed ជាអ្នកត្រួសត្រាយក្នុងការបើកចំហទិន្នន័យសហគមន៍ និងអ្នកបង្កើតផែនទីដ៏ប្រណិត ព្រមទាំងឧបករណ៍ផ្សេងៗសម្រាប់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ អង្គការស្បៀងអាហារ និងកសិកម្ម ធនាគារពិភពលោក និងស្ថាប័នផ្សេងៗទៀតជាច្រើន។

ប្រភព: www.goxi.org

តទៅទំព័រ ៤

## សហគមន៍អឺរ៉ុបឯកភាពជម្រុញឲ្យមានតម្លាភាពពីក្រុមហ៊ុន ប្រេង ឧស្ម័ន និងព្រៃឈើ

ដោយ Marc Hall

ការបង់ប្រាក់ក្នុងបរិមាណច្រើនជាង €១០០.០០០ ជូនរដ្ឋាភិបាលក្នុងប្រទេសសម្បូរធនធាន ត្រូវតែធ្វើការប្រកាស ដូចដែលសហគមន៍អឺរ៉ុបឯកភាពលើច្បាប់ជាគោលប្រឆាំងនឹងការគេចពន្ធ និងអំពើពុករលួយ។

សហគមន៍អឺរ៉ុបបានអនុម័តច្បាប់ថ្មីក្នុងគោលបំណងពង្រឹងតម្លាភាពការបង់ប្រាក់ពីឧស្សាហកម្មប្រេង និងឧស្ម័នជូនរដ្ឋាភិបាលជាចលនាមួយដែលត្រូវបានស្វាគមន៍ដោយ U2 frontman Bono ជា "ទំលុះភាពទាល់ច្រកនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រទាំងមូល" ស្តីពីអំពើពុករលួយក្នុងប្រទេសកំពុងអភិវឌ្ឍសម្បូរដោយធនធាន ។

រដ្ឋមន្ត្រី គណៈកម្មការ និងសភាអឺរ៉ុបកាលពីថ្ងៃអង្គារ បានបញ្ចប់កិច្ចចរចា ស្តីពីសេចក្តីបង្គាប់គណនេយ្យភាព ដោយឯកភាពលើសំណើ បន្ទាប់ពីមានការបញ្ចុះបញ្ចូលយ៉ាងខ្លាំងក្លាពីសំណាក់ឧស្សាហកម្ម និងអង្គការមិនមែនរដ្ឋាភិបាល។ កិច្ចព្រមព្រៀងនេះតម្រូវឲ្យក្រុមហ៊ុនអឺរ៉ុបរាយការណ៍អំពីការបង់ប្រាក់របស់ខ្លួនក្នុងបរិមាណច្រើនជាង €១០០.០០០ (£៨៥ ០០០) ជូនរដ្ឋាភិបាលក្នុងប្រទេសដែលក្រុមហ៊ុនកំពុងប្រតិបត្តិការ រួមមានពន្ធប្រមូលពីចំណូលផលិតកម្ម ឬ ប្រាក់កម្រៃសួយសាអាករ និងថ្លៃអាជ្ញាប័ណ្ណ ។

ផ្នែកប្រតិបត្តិសហគមន៍អឺរ៉ុបនឹងបង្គាប់ឲ្យក្រុមហ៊ុន ដាក់បង្ហាញការបង់ប្រាក់ ជូនរដ្ឋាភិបាលក្នុងកម្រិតគម្រោងមិនមែនតាមកម្រិតរបស់រដ្ឋាភិបាលទេ បង្ហាញនូវប្រភពនៃចំណូលរបស់រដ្ឋាភិបាលពីពន្ធពីឧស្សាហកម្មនិស្សារណកម្ម ឬព្រៃឈើ ។

បូណូ ជាអ្នកចម្រៀង និងជាសហស្ថាបនិកក្រុមយុទ្ធនាការលុបបំបាត់ភាពក្រីក្រ បាននិយាយថា "មេដឹកនាំអឺរ៉ុបបានបោះជំហានទៅមុខ និងនាំឲ្យមានការទំលុះភាពទាល់ច្រកនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រទាំងមូលនារាត្រីនេះ" ។ តម្លាភាពជាវ៉ាក់សាំងមួយក្នុងចំណោមវ៉ាក់សាំងល្អៗបំផុតប្រឆាំងនឹងអំពើពុករលួយ ហើយថាបច្ចុប្បន្នប្រជាពលរដ្ឋនៅទូទាំងពិភពលោក យល់ដឹងអំពីគុណតម្លៃនៃធនធានរបស់ប្រទេសខ្លួន"។

កិច្ចព្រមព្រៀងក៏នឹងកាត់បន្ថយនូវការិយាធិបតេយ្យច្រើនហួសហេតុសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) ដោយការធ្វើឲ្យមានភាពងាយស្រួលនូវក្បួនគណនេយ្យ ។ កិច្ចព្រមព្រៀងនេះ គឺលើសពីច្បាប់ដាក់បង្ហាញដែលបានអនុម័តដោយសហរដ្ឋអាមេរិកកាលពីឆ្នាំមុនដោយរួមបញ្ចូលនូវឧស្សាហកម្មព្រៃឈើ ជាមួយនិងប្រតិបត្តិការរ៉ែ និងប្រេងកាត។ លោក Michael Barnier សមាជិកគណកម្មការអឺរ៉ុបសម្រាប់ទីផ្សារផ្ទៃក្នុង មានប្រសាសន៍ថា "កិច្ចព្រមព្រៀងនឹងនាំមកនូវសករាជថ្មីនៃតម្លាភាពចំពោះឧស្សាហកម្ម ដែលជានិច្ចកាលបំពេញការងារជាសម្ងាត់ និងជួយប្រឆាំងជាមួយការគេចពន្ធ និងអំពីពុករលួយ ក៏ដូចជាបង្កើតឲ្យមានក្របខ័ណ្ឌច្បាប់សម្រាប់ទាំងក្រុមហ៊ុន និងរដ្ឋាភិបាលទទួលខុសត្រូវលើការប្រើប្រាស់ចំណូលបានមកពីធនធានធម្មជាតិ" ។

ប្រភព: The Guardian

## ហ្វីលីពីនប្រតិបត្តិគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម

រដ្ឋាភិបាលប្រទេសហ្វីលីពីន សភារ៉ែហ្វីលីពីន និង អង្គការBantay Kita ស្វាគមន៍ទៅនឹងការសម្រេចចិត្តរបស់រដ្ឋបាលអាគីណូដើម្បីប្រតិបត្តិគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) នៅក្នុងប្រទេសហ្វីលីពីន ដែលនេះនឹងធ្វើឲ្យកាន់តែមានតម្លាភាពគណនេយ្យភាពក្នុងការបង់ប្រាក់ ការប្រមូល និងការប្រើប្រាស់ចំណូលពន្ធ ព្រមទាំងចំណូលផ្សេងៗទៀត ពីឧស្សាហកម្មនិស្សារណកម្ម រួមចំណែកជានាផ្តល់ជាប្រយោជន៍ដល់ប្រទេស និងប្រជាពលរដ្ឋរបស់ខ្លួន។

ការទទួលយកមកប្រតិបត្តិនូវគំនិតផ្តួចផ្តើមនេះ យើងខ្ញុំសូមសង្កត់ធ្ងន់ថាចំនុចសំខាន់របស់EITI គឺជាគំរូនៃកិច្ចពិភាក្សា និងសហប្រតិបត្តិការដោយសេរី បើកចំហ មានការចូលរួម និងដោយស្មោះត្រង់រវាងរដ្ឋាភិបាល ក្រុមហ៊ុន និងសង្គមស៊ីវិល។ យើងប្រើប្រាស់ (EITI) ដែលជាបទដ្ឋានអន្តរជាតិមួយសម្រាប់ការបង្ហាញអំពីចំណូល ដើម្បីសម្រេចឲ្យបានតាមគោលបំណងនេះ។

ពាក់ព័ន្ធនឹងករណីនេះដែររដ្ឋាភិបាលប្រទេសហ្វីលីពីន សភារ៉ែហ្វីលីពីន និងអង្គការ Bantay Kita បានឯកភាពសហការអនុវត្ត EITI ។ យើងបានបង្កើតក្រុមអ្នកពាក់ព័ន្ធចម្រុះបណ្តោះអាសន្ន ដែលដឹកនាំរាល់សកម្មភាពចាំបាច់ទាំងឡាយ ឆ្ពោះទៅរកការបំពេញពាក្យសុំចូលជាបេក្ខភាព EITI ឲ្យបានមុនចុងឆ្នាំ ២០១២ ។

ក្រុមប្រឹក្សាភិបាលអន្តរជាតិរបស់ EITI បានប្រកាសនូវតម្រូវការចំនួនប្រាំ សម្រាប់ប្រទេសដែលមានបំណងចូលជាបេក្ខភាព EITI ដែលក្នុងនោះ តម្រូវការចំនួនបីត្រូវបានបំពេញឲ្យហើយជាស្រេចៈ រដ្ឋាភិបាលត្រូវចេញសេចក្តីថ្លែងការណ៍ឲ្យបានច្បាស់លាស់ជាសាធារណៈ អំពីបំណងប្រតិបត្តិ EITI ប្តេជ្ញាចិត្តបំពេញការងារជាមួយសង្គមស៊ីវិល និងក្រុមហ៊ុនចំពោះគំនិតផ្តួចផ្តើមនេះ និងចាត់តាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយរូបសម្រាប់ដឹកនាំ EITI ។

យើងខ្ញុំជាសមាជិករបស់ EITI ហ្វីលីពីនបណ្តោះអាសន្នអាចមានទស្សនៈ និងបទពិសោធន៍ផ្សេងៗគ្នា។ ប៉ុន្តែថ្ងៃនេះយើងបានរួបរួមគ្នា ជ ម្រុ ញឲ្យមានតម្លាភគណនេយ្យភាពកាន់ តែប្រសើរ ព្រមទាំងកិច្ចពិភាក្សាបើកចំហក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងការប្រមូល និងការបងពន្ធ ព្រមទាំងចំណូលពីឧស្សាហកម្មនិស្សារណកម្ម ។

ប្រភព: www.gov.ph

មកពីទំព័រ ៦ តស៊ូជីវិត...

ជាការងាររបស់ខ្ញុំទេប៉ុន្តែពេលដែលខ្ញុំបានចូលរួមក្នុងវិស័យនេះយ៉ាងពេញទំហឹង ខ្ញុំយល់ ថាគ្រប់គ្នាគួរ តែចូលរួម ដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនឯងផ្ទាល់ និងជាប្រយោជន៍សម្រាប់ប្រទេសជាតិ ។ ខ្ញុំបានដឹងថា ចំណូលពីឧស្សាហកម្មនិស្សារណកម្មគឺច្រើនដែលអាចធ្វើឲ្យប្រទេសមួយដែលជាប្រទេសក្រីក្រក្លាយជាប្រទេសមាន សេដ្ឋកិច្ចរីកចម្រើនក្នុងលក្ខខណ្ឌដែលចំណូលនោះត្រូវបានគ្រប់គ្រងបានត្រឹមត្រូវ បើមិន ដូច្នេះទេ គឺត្រូវជួបប្រទះនឹងបណ្ដាសារធនធានជាក់ជាមិនខាន ។ ខ្ញុំក៏បានកត់សំគាល់ផងដែរថា ករណីនេះគឺត្រូវកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យបានដល់កម្រិតមួយទាបបំផុតដែលអាចធ្វើទៅបាន” ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ បើទោះបីជា នីន បានទទួលចំណេះដឹងច្រើនពីវិស័យឧស្សាហកម្មនិស្សារណកម្មនេះ ក៏ប៉ុន្តែចំណេះដឹងនេះនៅមិនទាន់ស៊ីជម្រៅនៅឡើយទេ ដែល អាចឲ្យ នីន ឆ្លើយតបទៅនឹងសំណួរបច្ចេកទេស ពេលដែលត្រូវបានសួរក្នុងអំឡុងពេលធ្វើការគៀងគរនោះទេ ។

នីន បាននិយាយថា “តាមរយៈពាក្យសម្ដី ខ្ញុំពុំអាចរៀបរាប់ឲ្យបានក្បោះក្បាយថាខ្ញុំដឹងគុណ និងរីករាយយ៉ាងណាដែលទទួលបានការណែនាំពីសំណាក់សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ។ បើខ្ញុំមិនត្រូវបានឲ្យមកបំពេញការងារជាអ្នកស្ម័គ្រចិត្តទេ ខ្ញុំមិនអាចទទួលបានចំណេះដឹងអំពីឧស្សាហកម្មនិស្សារណកម្មដូចជាសព្វថ្ងៃនេះទេ”។

នីន និយាយទៀតថា “ជាចុងក្រោយ ខ្ញុំសូមអំពាវនាវដល់ទីភ្នាក់ងារម្ចាស់ជំនួយ សូមមេត្តាបន្តគាំទ្រដល់ការងាររបស់សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ជាសម្ព័ន្ធភាពតែមួយគត់ដែលបំពេញការងារវិស័យឧស្សាហកម្មនិស្សារណកម្ម នាំយកមកនូវតម្លាភាព និងគណនេយ្យភាពលើចំណូលបានមកពីប្រេងឧស្ម័ន និងរ៉ែ”។



មកពីទំព័រ ១ ការធ្វើអាជីវកម្ម...

ទៅឲ្យក្រុមហ៊ុនអន្តរជាតិរួចអស់ហើយ និងតំបន់ដែនគោកមាន៣ប្លុក គឺមានប្លុកទី១២ ទី១៥ និងទី១៧ ក៏ត្រូវបានផ្ដល់អាជ្ញាប័ណ្ណរួចហើយដែរ។ ជាមួយគ្នានោះដែរប្រទេសកម្ពុជាក៏មានតំបន់ត្រួតស៊ីគ្នារវាងកម្ពុជា និងថៃដែលជាតំបន់មានសក្ដានុពលបំផុត ។

ចំណែកលោក Dinis Schrey តំណាងមូលនិធិខុនរ៉ាដប្រចាំកម្ពុជាបាននិយាយថា បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាហាក់ដូចជាសម្ដែងនូវការបារម្ភច្រើនអំពីការរុករកប្រេងជាពិសេសនៅក្នុងវិស័យឧស្សាហកម្មនេះ ប៉ុន្តែផ្ដោតលើបញ្ហានៃការគ្រប់គ្រង និងប្រាក់ចំណូល។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការព្យាករណ៍ថា ចំណូលពីវិស័យនេះអាចមានកំណើនជាបន្តបន្ទាប់ហើយគេបានធ្វើការព្យាករណ៍ថា ដល់ឆ្នាំ ២០២១ អាចកើនដល់ ១,៧ ពាន់លានដុល្លា។ ប៉ុន្តែការព្យាករណ៍បែបនេះក៏វាមិនទាន់ប្រាកដប្រជាដែរ ដោយសារវាអាស្រ័យទៅលើការវិវត្តន៍ទៅលើតម្លៃប្រេងនៅក្នុងពិភពលោកផងដែរ។ ប៉ុន្តែបើសិនជាការព្យាករណ៍របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិជាការត្រឹមត្រូវនោះ គឺថា វាអាចជួយដល់សេដ្ឋកិច្ចរបស់កម្ពុជា និងជួយទៅដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសផងដែរ ។

លោក Denis Schrey បានបន្តថា ផ្ទុយទៅវិញបើសិនជាការគ្រប់គ្រងមិនបានត្រឹមត្រូវ និងអំពើពុករលួយគឺវានាំទៅដល់ហានិយភ័យដល់កម្ពុជា ហើយពេលហ្នឹងវាធ្វើឲ្យគម្លាតរវាងអ្នកមាន និងអ្នកក្រនៅក្នុងប្រទេសកម្ពុជាកាន់តែធ្ងន់ធ្ងរ។ បើនិយាយពីវិស័យប្រេងនៅកម្ពុជាប្រៀបធៀបជាមួយនឹងឧស្សាហកម្មផ្សេងទៀតឃើញថា វានៅក្មេងខ្ចីនៅឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយភាគីពាក់ព័ន្ធទាំងអស់គេយល់ឃើញថា វិស័យនេះអាចរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងប្រទេស ។

លោកលើកឡើងថា ដោយសារតែការមើលឃើញអំពីសក្ដានុពលប្រេង និងឧស្ម័ន ក្រុមហ៊ុនបរទេសបានមកវិនិយោគរុករកប្រេង និងឧស្ម័ននៅក្រោមដី ដែលត្រូវបានគេចាត់ទុកជាមាសពណ៌ខ្មៅមួយ។ រហូតមកដល់ពេលនេះមានក្រុមហ៊ុនបរទេសមួយចំនួនដែលមកពីសហរដ្ឋអាមេរិក អូស្ត្រាលី ចិន ឥណ្ឌូណេស៊ី ជប៉ុន ហើយនិងក្រុមហ៊ុនកូរ៉េផងដែរបានកំពុងរុករករ៉ែប្រេង និងឧស្ម័ន នៅក្នុងប្លុកពី A ដល់ F នៅក្នុងសមុទ្រក៏ដូចជានៅប្លុកលើដីគោកមួយចំនួន។

លោក Denis Schrey បានបន្តទៀតថា ជាមួយគ្នានេះដែរ រដ្ឋាភិបាលហាក់ដូចជាមានការផ្សព្វផ្សាយតិចតួចបំផុតអំពីព័ត៌មានរបស់ក្រុមហ៊ុនដែលមកវិនិយោគ និងមិនទាន់ច្បាស់លាស់នៅឡើយ។ នៅក្នុងពិភពលោកយើងឃើញអំពើពុករលួយគឺតែងតែកើតមាននៅគ្រប់ដំណាក់កាលនៃការប៉ុនប៉ងដើម្បីរុករកយករ៉ែធម្មជាតិ។ លោកបានបញ្ជាក់ថា លោកមានជំនឿជឿ ជាក់ថា អាជ្ញាធរប្រេងកាតជាតិ ក៏ដូចជាគណៈរដ្ឋមន្ត្រីនឹងធ្វើយ៉ាងណាដើម្បីបង្ហាញនូវតម្លាភាព ហើយព្យាយាមបង្ហាញនូវអ្វីដែលខ្លួនបានធ្វើកន្លងមកដើម្បីឲ្យសាធារណជនបានដឹងផងដែរ ។ ជាមួយគ្នានេះ តួនាទីរបស់រដ្ឋសភាជាតិ ហើយនិងអង្គការសង្គមស៊ីវិលជួយរួមចំណែកដ៏សំខាន់នៅក្នុងការធ្វើយ៉ាងណាដើម្បីធានានូវតម្លាភាពនៅក្នុងបញ្ហាចាត់ចែងរុករករ៉ែធម្មជាតិនេះ ។

ទាក់ទងការលើកឡើងខាងលើនេះ មិនអាចសុំការអត្ថាធិប្បាយពីមន្ត្រីអាជ្ញាធរជាតិប្រេងកាត កម្ពុជាបានទេ៕

# តស៊ូក្នុងជីវិតដើម្បីទទួលបាននូវចំណេះដឹងផ្នែកឧស្សាហកម្មនិស្សារណកម្ម

ដោយ CRRT



នីន កំពុងដាំកូនឈើ(រូបថត CRRT)

កើ តមកក្នុងគ្រួសារកសិករ ក្នុងខេត្តដែលមា នកា រ អភិវឌ្ឍតិចតួចឺជាសុបិនដែលពិបា ក ប្រែក្លាយឲ្យទៅជាការពិត។ ការរស់នៅទាំងត្រដរបានព្រឹកខ្វះល្ងាចជាបញ្ហាចោទមួយទៀត។ ការស្វែងរកចំណេះដឹងថ្នាក់ឧត្តមសិក្សាក៏ជួបនឹងវិបត្តិខ្វះថវិកា។

កញ្ញា ឈឹម នីន បានចាប់ផ្តើការសិក្សាតាំងពីកម្រិតបឋម រហូតដល់កម្រិតខ្ពស់នៅស្រុកកំណើត មុនពេលមករស់នៅក្នុងទីក្រុង ដែលជាកន្លែងចំណេះដឹងត្រូវបានចាត់ទុកជាអទិភាព។

បច្ចុប្បន្ន នីន ជានិស្សិតឆ្នាំទី៤ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ សិក្សាយកជំនាញសង្គមវិទ្យា ។

នីន នៅមិនទាន់អាចរ៉ាប់រងជីវភាពដោយខ្លួនឯងបាននៅឡើយទេ ដូចនេះសិក្សាផង បំពេញការងារជាអ្នកស្មគ្រ័ចិត្តផង ជាករណីមួយមិនអាចចៀសបាន។

ចាប់តាំងតែពី នីន បានចូលមករស់នៅក្នុងទីក្រុង នីន បានលឺអំពីគម្រោងអភិវឌ្ឍវិនិយោគជាច្រើនអំពីឧស្សាហកម្មនិស្សារណកម្ម ហើយ តែងតែឆ្ងល់ និងយកមកគិតថា តើពាក្យថាឧស្សាហកម្មនិស្សារណកម្មមានអត្ថន័យយ៉ាងដូចម្តេច។ ដោយសារតែចិត្តចង់ដឹងខ្លាំង នីន តាំងចិត្តធ្វើការស្រាវជ្រាវ ស្វែងរកការងារពាក់ព័ន្ធរហូតដល់ចុងក្រោយ នីន បានទៅបំពេញការងារជាមួយអង្គការកម្មវិធីអភិវឌ្ឍន៍ ធនធានយុវជន ជាអ្នកស្ម័គ្រចិត្តក្រុមយុវជនស្នូលនៃគម្រោងតម្លាភាពឧស្សាហកម្មនិស្សារណកម្ម និងបម្រែបម្រួលអាកាសធាតុ ។ នីន បានទទួលចំណេះដឹងយ៉ាងច្រើនពីវិធីសម្របសម្រួលក្នុងសិក្ខាសាលាអំពីឧស្សាហកម្មនិស្សារណកម្ម និងនៅក្នុងក្រុមការងារក្នុងទីក្រុង និងតាមទីរួមខេត្ត។ នីន អាចសរសេរលិខិតអញ្ជើញ លិខិតថ្លែងអំណរគុណ ព្រមទាំងរៀបចំផែនការដំណើរទស្សនៈកិច្ចសិក្សា ធ្វើបទសំភាសន៍រួមទាំងការប្រមូលទិន្នន័យ។

នីន បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកិច្ចពិភាក្សាអន្តរជំនាន់ផ្សេងៗជាច្រើនស្តីអំពី សកម្មភាពសង្គម បរិស្ថាន និងរ៉ែ។ នីន ក៏បានទទួលចំណេះដឹងតាមរយៈវគ្គសិក្សាស្តីពីកញ្ចប់ស្ថិតិវិទ្យាសាស្ត្រសង្គម គណនេយ្យភាពសង្គមក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម ឧស្សាហកម្មនិស្សារណកម្ម រ៉ែ ប្រេង និងឧស្ម័ន បម្រែបម្រួលអាកាសធាតុ និងមេរៀនផ្សេងៗទៀត។

មិនយូរប៉ុន្មាន កិច្ចសន្យាការងារជាអ្នកស្ម័គ្រចិត្តរបស់ នីន ត្រូវ បានបញ្ចប់ ប៉ុន្តែដោយសារតែមានការប្តេជ្ញាចិត្ត និង ការលះបង់ខ្ពស់ នីនបានព្យាយាម មិនគិតពីកានឿយហត់ រហូតដល់ទទួលបានការងារមួយទៀតជាអ្នកស្ម័គ្រចិត្ត ជាមួយសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ជាសម្ព័ន្ធភាពដែលមានជំនាញ បំពេញការងារជាមួយសមាជិកដើម្បីធានាឲ្យមានតម្លាភាព និងគណនេយ្យភាពលើចំណូលបានមកពីប្រេង ឧស្ម័ន និងរ៉ែ។

នីន បាននិយាយថា "ខ្ញុំចាប់ផ្តើមយល់ និងទទួលបានចំណេះដឹងអំពីឧស្សាហកម្មនិស្សារណកម្ម ពេលដែលខ្ញុំបំពេញការងារផងសិក្សាផង តាមរយៈការងារស្ម័គ្រចិត្ត។ ខ្ញុំមានអារម្មណ៍ថា នេះជាការទទួលខុសត្រូវ របស់ខ្ញុំក្នុងនាមជាប្រជាពលរដ្ឋមួយរូបរស់នៅក្នុងប្រទេសដែលសម្បូរធនធានប្រេង ឧស្ម័ន និងរ៉ែ ដើម្បីស្វែង យល់ អំពីសារៈសំខាន់ ហើយនឹងអាចចូលរួមចំណែកនៅពេលបូមប្រេងក្នុងឆ្នាំ ២០១៦ ។ ខ្ញុំមានសំណាងណាស់ ដែលទទួលបានការបណ្តុះបណ្តាលជាច្រើនដូចនេះ ។ ខ្ញុំមាន មោទនភាព និងរីករាយដោយបានយល់ដឹង និងមានលទ្ធភាពចែករំលែកក្នុងចំណោមមិត្តភក្តិព្រមទាំងញាតិសណ្តានផ្សេងៗទៀតអំពីឧស្សាហកម្មនិស្សារណកម្ម" ។

តាមរយៈចំណេះដឹងដែលទទួលបាន នីនបានគៀងគរ និងចែករំលែកធនធានជាមួយនិស្សិតសាកលវិទ្យាល័យផ្សេងៗទៀត ក៏ដូចជាសមាជិកគាំទ្រតាមវិធីផ្សេងៗដែលអាចធ្វើទៅបាន ដូចជាតាមរយៈវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ និងសូម្បីតែនៅតាមទីកន្លែងកំសាន្តនានា។ នីន បាននិយាយថា " ការសិក្សាគឺមិនមានការកំណត់ពីទីកន្លែងទេ! ទីណាដែលយើងចង់សិក្សាទីនោះជាកន្លែងសិក្សា។ ការដែលចាត់ទុកទីកន្លែងណាមួយជាកន្លែងសិក្សាហើយក្រៅពីទីនោះមិនអាចសិក្សាបាន ពុំមែនជាគំនិតល្អទេដោយសារថាទំរាំដល់កន្លែងបានកំណត់ យើងអាចភ្លេចនូវអ្វីដែលយើងចង់ចែករំលែក" ។

នីន បាននិយាយបន្ថែមថា "ខ្ញុំតែងតែគិតថា ឧស្សាហកម្មនិស្សារណកម្មមិនមែន

តទៅទំព័រ ៥

MISEREOR • DAS HILFSWERK | USAID FROM THE AMERICAN PEOPLE | REVENUE WATCH INSTITUTE | Oxfam | NORWEGIAN PEOPLE'S AID



ស៊ីអារអាធី: ផ្ទះលេខ ៨៨ ផ្លូវលេខ៤៦៨ សង្កាត់ទួលទំពូង I ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ: ៨៥៥-២៣-២១៧-៦០៧ គេហទំព័រ: www.crrt-cambodia.org